# ដំណើរការ និងបញ្ហាប្រឈមនៃវិសហមជ្ឈការនៅកម្ពុជា៖ ករណីសិក្សាលើការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជន

## សេចក្តីផ្តើម

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាបានឈានចូលដំណាក់កាលថ្មីមួយ ទោះបីកន្លងមកទទួលបានលទ្ធផលចម្រុះក្តី។ ការសង្កត់ធ្ងន់ឡើងវិញលើកំណែទម្រង់ស៊ីជម្រៅដោយគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ បានជួយជំរុញកំណែទម្រង់វិមជ្ឈការទៅមុខទៀត។ ចាប់ពីឆ្នាំ២០១៥ មក នៅថ្នាក់ស្រុក និងថ្នាក់ក្រុងមានការរៀបចំប្រព័ន្ធរដ្ឋបាលឡើងវិញ តាមរយៈ ការផ្ទេរមុខងារផ្សេងៗពីក្រសួងជំនាញ ទៅឲ្យរដ្ឋបាលស្រុក និងរដ្ឋបាលក្រុង។ ដូចរដ្ឋាភិបាលបានប្រកាសឡើង ការផ្ទេរមុខងារមានគោលដៅធ្វើឲ្យ ស្ថាប័នទទួលបន្ទុកផ្តល់សេវាកាន់តែខិតទៅជិតប្រជាជនដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន និងពង្រឹងគណនេយ្យភាព (Sar 2015)។ ក្នុងស្ថានភាពនេះ ដំណាក់កាលថ្មីនៃកំណែទម្រង់វិមជ្ឈការ គឺជា កិច្ចប្រឹងប្រែងសម្រេចឲ្យបានគោលដៅរំពឹងទុកនៃការផ្តល់សេវាតាមបែបវិមជ្ឈការ។

ចំណុចប្លែកពីមុននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមួយរយៈចុងក្រោយនេះ គឺការបង្ហាញច្បាស់ជាសាធារណៈនូវឆន្ទៈនយោបាយ។ តួយ៉ាង អនុប្រធានលេខាធិការដ្ឋាន គជអប បានកំណត់យកការផ្ទេរមុខងារ[១] ធ្វើជាចំណុចស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយប្រកាសថា "បើនិយាយពីកម្មវិធីកំណែទម្រង់ គឺនិយាយពីការផ្ទេរមុខងារ និង ធនធាន ប្រសិនបើគ្មានការផ្ទេរមុខងារ និងធនធាន គឺគ្មានកម្មវិធីកំណែទម្រង់" (NCDD 2015)។ ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន គជអប ក៏បានថ្លែងថា ការយឺតយ៉ាវក្នុងដំណាក់កាលមុននៃកំណែទម្រង់ បណ្តាលមកពីភាពរារែករបស់ក្រសួងជំនាញនានា ហើយក៏បានជំរុញក្រសួងទាំងនោះ ឲ្យយកចិត្តទុកដាក់ ទៅលើការងារកំណែទម្រង់ (Sar 2015)។ តាមរយៈការពន្លឿនការផ្ទេរមុខងារ រាជរដ្ឋាភិបាលហាក់ដូចបានទុកមួយឡែកនូវ ក្តីបារម្ភពីភាពមិនស៊ីគ្នារវាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងទំនួលខុសត្រូវកាន់តែធំឡើង ហើយរាជរដ្ឋាភិបាលក៏កាន់តែមានឆន្ទៈទទួលស្គាល់ពីធាតុផ្សំចាំបាច់ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចជា សិទ្ធិអំណាចធ្វើការសម្រេចចិត្ត និងធនធាន ជាដើម។ ផ្អែកលើការប្តេជ្ញាចិត្តនេះ គេអាចនិយាយបានថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅពេលនេះ លែងគ្រាន់តែជាវិមជ្ឈការផ្នែកនយោបាយ ដូចវិមជ្ឈការកម្រិតឃុំសង្កាត់ កាលពីមុនទៀតហើយ ប៉ុន្តែវាក៏ជា វិមជ្ឈការផ្នែករដ្ឋបាល ផងដែរ។

## សាវតា: បញ្ហាកាកសំណល់ និងតម្រូវការឲ្យមានការផ្ទេរមុខងារ

ទន្ទឹមគ្នានឹងកំណើនប្រជាជន និង នគរូបនីយកម្មយ៉ាងឆាប់រហ័ស បញ្ហាកាកសំណល់នៅទីប្រជុំជន និងបញ្ហាសុខភាពសាធារណៈផ្សេងៗក៏កើនឡើង ដោយចោទខ្លាំងជាពិសេសនៅរាជធានីភ្នំពេញដែលជាទីក្រុងធំជាងគេនៅកម្ពុជា និងមានការផលិតកាកសំណល់រឹងជាង ១000តោនជារៀងរាល់ថ្ងៃ (Blue Media Cambodia 2015)។ ដោយសារបញ្ហាប្រឈមទាំងនេះ និងគោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រោយពេលបោះឆ្នោតឆ្នាំ២០១៣ ក្រសួងបរិស្ថាន បានសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញនូវប្រកាសអន្តរក្រសួង ក្នុងឆ្នាំ២០១៥ ស្តីពី ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ នៅតាមទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិកា ៥ លានដុល្លារ ត្រូវបានវិភាជទៅឲ្យ ២៦ ក្រុង ទូទាំងប្រទេស ដោយផ្អែកទៅតាមចំនួនប្រជាជននៃក្រុងនីមួយៗ។ ការវិភាជថវិកានេះ បានបើកផ្លូវឲ្យមានការផ្ទេរមុខងារគ្រប់គ្រងកាកសំណល់រឹង ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់មកទៀតរាជរដ្ឋាភិបាល បានចេញ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដើម្បីដាក់ឲ្យដំណើរការថវិកានេះ ដោយកំណត់ភារកិច្ចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺ រដ្ឋបាលរាជធានី ក្រុង និងស្រុក ។ ការសិក្សានេះផ្តោតតែលើការគ្រប់គ្រងកាកសំណល់រឹងនៅថ្នាក់ក្រុង ពីព្រោះនៅពេលបច្ចុប្បន្នថវិកាត្រូវបានវិភាជឲ្យតែរដ្ឋបាលក្រុងប៉ុណ្ណោះ។

## សំណួរស្រាវជ្រាវ

ការផ្ទេរមុខងារដែលចាប់ផ្តើមឡើងក្នុងឆ្នាំ២០១៥ ជាសញ្ញាបង្ហាញថា វិសហមជ្ឈការដែលគេទន្ទឹងរង់ចាំនោះបានចូលមកដល់ហើយ។ ដោយផ្អែកលើការវិភាគឯកសារ និងការធ្វើសម្ភាសន៍ស៊ីជម្រៅ ការសិក្សានេះមានគោលដៅលើកកម្ពស់ការយល់ដឹងពីស្ថានភាពនៃវិសហមជ្ឈការ ដោយព្យាយាមឆ្លើយនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

---

អត្ថបទនេះរៀបរៀងឡើងដោយ វង់ ម៉ាន់ ជាអ្នកស្រាវជ្រាវក្នុងផ្នែកអភិបាលកិច្ចនៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Vong Mun. 2017. "Progress and Challenges of Deconcentration in Cambodia: The Case of Urban Solid Waste Management." *Cambodia Development Review* 21 (2): 8-11។

១ ពាក្យនេះក៏ឃើញមានប្រើនៅក្នុងឯកសារនានារួមមាន ការផ្ទេរមុខងារ និងការកំណត់មុខងារឡើងវិញ។

***តើមានសិទ្ធិ និងទំនួលខុសត្រូវអ្វីខ្លះសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង ដែលត្រូវបានផ្ទេរវិសហមជ្ឈការទៅឲ្យរដ្ឋបាលក្រុង។ តើរដ្ឋបាលក្រុងប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ក្នុងការអនុវត្តសិទ្ធិ និងទំនួលខុសត្រូវទាំងនោះ។***

## គោលគំនិតសំខាន់ៗ

វិសហមជ្ឈការ ជាបែបផែនមួយ សម្រាប់ផ្ទេរការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបែបផែនមួយទៀតគឺ វិមជ្ឈការ។ នៅពេលមុខងារអ្វីមួយត្រូវបានធ្វើវិសហមជ្ឈការ គឺក្រសួងរក្សាទុកនូវសិទ្ធិអំណាចធ្វើ សេចក្តីសម្រេចផ្សេងៗផ្នែកគោលនយោបាយ និងថវិកា រីឯរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការអនុវត្តមុខងារ និងត្រួតពិនិត្យលើបុគ្គលិកដែលផ្ទេរមកពីក្រសួង។ មុខងារគឺជា សកម្មភាពជាសំណុំ ដូចជា ការគ្រប់គ្រងកាកសំណល់រឹង ការគ្រប់គ្រងមណ្ឌលសុខភាព ឬការថែទាំការផ្គត់ផ្គង់ទឹកស្អាតជនបទជាដើម ដែលរួមចំណែកដល់ដំណើរការនៃប្រព័ន្ធអភិបាលកិច្ច (Pak 2011)។ ការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងកំណែទម្រង់បច្ចុប្បន្ន រួមមាន ការប្រគល់មុខងារ និងការធ្វើប្រតិភូកម្មមុខងារ។ ការប្រគល់មុខងារ សំដៅដល់ "ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារ"។ ការធ្វើប្រតិភូកម្មមុខងារ សំដៅដល់ "ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម" (RGC 2012, 3)។ ជារួម ការប្រគល់មុខងារគឺជា វិសហមជ្ឈការក្នុងទម្រង់ស៊ីជម្រៅជាងការធ្វើប្រតិភូកម្មមុខងារ។ ការប្រគល់មុខងារផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាចច្រើនជាង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនដូចមានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។

## លទ្ធផលសិក្សា

### *ក្របខ័ណ្ឌច្បាប់: ទំនួលខុសត្រូវ សិទ្ធិ និងធនធាន*

ដំណើរការផ្ទេរមុខងារបាននាំមកនូវការផ្លាស់ប្តូរធំៗមួយចំនួន។ អនុក្រឹត្យឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជនបានកំណត់ឲ្យរដ្ឋបាលក្រុងនូវ ទំនួលខុសត្រូវធំៗ ៥ សម្រាប់ការគ្រប់គ្រងកាកសំណល់រឹង គឺ ១) រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និង ថវិកាប្រចាំឆ្នាំ ២)រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ៣) បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ៤) ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំណល់រឹងទីប្រជុំជន ៥) អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

ដើម្បីជួយទ្រទ្រង់ដល់ការអនុវត្តមុខងារ រដ្ឋបាលក្រុងត្រូវបានអនុញ្ញាតឲ្យ ១) ចេញជាដីកា ឬលិខិតបទដ្ឋាននានា ២) រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណង់រឹងទីប្រជុំជន ៣) ធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់ជាប់គ្នាក្នុងការផ្តល់សេវារួមគ្នា ៤) ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទៅឲ្យរដ្ឋបាលសង្កាត់ ឬប្រគល់សិទ្ធិទៅឲ្យសហគមន៍អនុវត្តមុខងាររងណាមួយ ឬមួយចំនួន ៥) កំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ៦) ប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ៧) អនុម័តលើសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ (RGC 2015)។

ចំពោះធនធានវិញ នៅឆ្នាំ២០១៥ ក្រុងនានាក្នុងការសិក្សានេះបានទទួលមូលនិធិពី ៤៥.០០០ដុល្លារ ទៅ ៩០.០០០ដុល្លារ អាស្រ័យទៅលើចំនួនប្រជាជននៅក្នុងក្រុងនីមួយៗ។ ថវិកានេះគឺជាការផ្លាស់ប្តូរមួយយ៉ាងសំខាន់ បើធៀបនឹងថវិកាដ៏តិចតួចរបស់អាជ្ញាធរខេត្តសម្រាប់ការគ្រប់គ្រងសំណល់រឹង នៅមុនពេលមានការផ្ទេរមុខងារ (Pak and Craig 2008)។ ម៉្យាងទៀត រដ្ឋបាលក្រុងនឹងអាចបង្កើតប្រាក់ចំណូលផ្ទាល់ តាមរយៈ កម្រៃសេវាប្រមូលសំរាម សំណល់រឹង។ ដោយផ្អែកលើ កម្រៃសេវាអតិបរមារៀបចំឡើងដោយក្រសួងជំនាញ រដ្ឋបាលក្រុងអាចកំណត់ កម្រៃសេវាសម្រាប់តំបន់របស់ខ្លួន ដោយផ្អែកលើប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល និងបរិមាណកាកសំណល់។ មុននឹងឈានដល់សេចក្តីសម្រេចនេះ រដ្ឋបាលក្រុងត្រូវពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់សេវា និងភាគីពាក់ព័ន្ធផ្សេងៗ។ រដ្ឋបាលក្រុងក៏មានភារកិច្ចរៀបចំយន្តការផ្សេងៗ សម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់ កម្រៃសេវា ផងដែរ។ ថ្វីបើមានការវិភាជថវិកាទៅឲ្យរដ្ឋបាលក្រុងក្តី ប៉ុន្តែនៅមិនទាន់មានការផ្ទេរបុគ្គលិកសម្រាប់មុខងារនេះទេ។

រដ្ឋបាលក្រុងបានប្រើប្រាស់កញ្ចប់ថវិកា សម្រាប់សកម្មភាពផ្សេងៗ ដើម្បីលើកសោភណភាពក្រុង រួមមាន ការប្រមូលសំរាម ការបោសសម្អាតផ្លូវសំខាន់ៗ ការកាត់តម្រឹមដើមឈើ ការដាក់ធុងសំរាម និងការដាក់បដាអប់រំផ្សេងៗ។ មានក្រុងមួយបានប្រើប្រាស់ថវិកាមួយភាគ ដើម្បីជួសជុលផ្លូវចូលទៅទីលានចាក់សំរាម។ លើកលែងតែក្រុងមួយនេះ ដែលប្រើប្រាស់ទម្រង់ចម្រុះរដ្ឋ-ឯកជនក្នុងការអនុវត្តមុខងារ ក្រុងឯទៀតៗបានជ្រើសយកវិធី ម៉ៅការទៅឲ្យអ្នកផ្តល់សេវាឯកជន ដែលក្រុងបានជ្រើសរើសតាមរយៈគណៈកម្មការលទ្ធកម្មរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពដូចបានរៀបរាប់ខាងលើ។ ក្នុងករណីនេះ រដ្ឋបាលក្រុងផ្តោតជាសំខាន់ទៅលើ ការត្រួតពិនិត្យលទ្ធផលការងាររបស់អ្នកម៉ៅការឯកជន។ នៅក្រុងមួយ ក្រុមប្រឹក្សាសង្កាត់ ត្រូវបានស្នើឲ្យជួយធ្វើការត្រួតពិនិត្យ ហើយ

ព័ត៌មានត្រូវរាយការណ៍ទៅឲ្យរដ្ឋបាលក្រុងតាមទូរស័ព្ទ។

### *ទំនាក់ទំនងរវាងស្ថាប័នរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ជំនួយគាំទ្រ និងការត្រួតពិនិត្យ*

នៅក្រោមរចនាសម្ព័ន្ធថ្មី តួនាទីថ្មីរបស់មន្ទីរបរិស្ថានខេត្ត ក្នុងការគ្រប់គ្រងកាកសំណល់រឹង រួមមាន៖ ១) លើកកម្ពស់ការយល់ដឹងពីបញ្ហាបរិស្ថាន ២) ចូលរួមកសាងផែនការគ្រប់គ្រងកាកសំណល់រឹង ៣) ជួយផ្ដល់មតិណែនាំផ្នែកបច្ចេកទេសលើគម្រោង ឬសំណើគ្រប់គ្រងកាកសំណល់រឹង ៤) តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការ គ្រប់គ្រងកាកសំណល់រឹង ៥) រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីស្ថានភាព និងដំណើរការគ្រប់គ្រងកាកសំណល់រឹង (RGC 2015)។ ដោយសារទំនួលខុសត្រូវទាំងនេះ រដ្ឋបាលក្រុង អាចចូលរួមកាន់តែមានប្រយោជន៍ជាមួយមន្ទីរ បើធៀបនឹងកាលពីមុនដែលទំនាក់ទំនងរវាងភាគីទាំងពីរ មានត្រឹមតែការចូលរួមម្ដងម្កាលក្នុងព្រឹត្តិការណ៍សាធារណៈទាក់ទងនឹងបរិស្ថានតែប៉ុណ្ណោះ។

ជាក់ស្ដែងរហូតមកទល់បច្ចុប្បន្ន ទំនាក់ទំនងរវាងរដ្ឋបាលក្រុងជាមួយនឹង មន្ទីរបរិស្ថាន មិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់ទេ នៅតាមក្រុងដែលបានចុះសិក្សា។ នៅក្រុងមួយ អ្នកឆ្លើយតបម្នាក់នៅមន្ទីរបរិស្ថាន បានបង្ហាញពីការមិនពេញចិត្តជាមួយនឹងរដ្ឋបាលក្រុង ដោយត្អូញត្អែរថា រដ្ឋបាលក្រុងកាន់តែមានស្វ័យភាព និងសិទ្ធិអំណាចសម្រេចអារកាត់ច្រើនឡើង។ គាត់មានប្រសាសន៍ថា៖ "ពួកគេមិនស្ដាប់មន្ទីរជំនាញ ឬខេត្តទេ"។ គាត់ក៏រារែកក្នុងចិត្តចំពោះផែនការជ្រើសរើសអ្នកផ្ដល់សេវាថ្មីដែរ ព្រោះគាត់គិតថា អ្នកផ្ដល់សេវាសព្វថ្ងៃបានជួយច្រើនណាស់ ដោយបានឆ្លើយតបតាមសំណើផ្សេងៗរបស់មន្ទីរ ហើយគាត់មិនទុកចិត្តថាអ្នកថ្មីអាចធ្វើបានដូចគ្នាទេ។ គាត់ថែមទាំងបានលើកមតិថា មន្ទីរបរិស្ថាន គួរតែទទួលបានកញ្ចប់ថវិកា មិនមែនរដ្ឋបាលក្រុងទេ។ រហូតមកដល់ពេលថ្មីៗនេះ មន្ទីរបរិស្ថាននៅខេត្តនោះ គឺជាអ្នកត្រួតពិនិត្យលើ អ្នកផ្ដល់សេវាឯកជន ដែលត្រូវបានជ្រើសរើសដោយអតីតប្រធានមន្ទីរ។

នៅក្រុងមួយទៀត មន្ទីរបរិស្ថាន មិនសូវបានពាក់ព័ន្ធច្រើនក្នុងការផ្ទេរមុខងារនេះទេ។ ការតវ៉ា គឺមានពីរដ្ឋបាលក្រុងមកវិញ។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងបានត្អូញត្អែរថា មន្ទីរបរិស្ថានខេត្តមិនបានជួយអ្វីច្រើនទេក្នុងការគ្រប់គ្រងកាកសំណល់ ទាំងនៅមុនពេល និងក្រោយពេល ផ្ទេរមុខងារ។ គាត់មានប្រសាសន៍ថា "ខ្ញុំធ្លាប់សួរពួកគេថា តើថវិកាអាចយកទៅប្រើសម្រាប់សកម្មភាពលើកកម្ពស់ការយល់ដឹងនិងទិញធុងសំរាមបានដែរឬទេ ពីព្រោះប្រកាសមិនបានចែងច្បាស់ ហើយពួកគេប្រាប់ថា ពួកគេក៏មិនដឹងដែរ"។

នៅក្រុងមួយផ្សេងទៀត មន្ទីរបរិស្ថាន មានភាពតឹងតែង។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងបាននិយាយថា សំណើរបស់គាត់លើការប្រើប្រាស់ថវិកា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ត្រូវបានខាងមន្ទីរច្រានចោលដោយអះអាងថា ថវិកានេះគឺប្រើសម្រាប់តែការផ្ដល់សេវា និងធ្វើអន្តរាគមន៍ប៉ុណ្ណោះ ថ្វីបើសាម៉ីខ្លួនគាត់យល់ឃើញថា អនុក្រឹត្យបានអនុញ្ញាតក្ដី។ គាត់បានសារភាពថា ធ្វើតាមអ្វីដែលបុគ្គលនិយាយ វាសំខាន់ជាងធ្វើតាមអ្វីដែលមានចែងលើក្រដាស ពីព្រោះ ពួកគេមានសិទ្ធិអំណាចអនុម័តលើសំណើថវិកា។ តាមរយៈប្រសាសន៍នេះ គាត់ហាក់បង្ហើបឲ្យដឹងពី ឥទ្ធិពលនៃមន្ទីរបរិស្ថាន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅលើដំណើរការផ្ទេរថវិកា។ តាមច្បាប់កំណត់ រដ្ឋបាលក្រុងត្រូវដាក់សំណើថវិកា ព្រមទាំងផែនការសកម្មភាព សម្រាប់គ្រប់គ្រងកាកសំណល់រឹង ជូនទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរបរិស្ថាន ។

សម្រាប់ក្រសួងបរិស្ថានវិញ តួនាទីចម្បងគឺ ធ្វើអធិការកិច្ចជាទៀងទាត់លើការអនុវត្តមុខងារ។ ក្នុងករណីមានការរំលោភលើសេចក្ដីណែនាំពីការគ្រប់គ្រងកាកសំណល់រឹង ក្រសួងអាចស្នើទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យផ្អាកការផ្ទេរថវិកាទៅឲ្យរដ្ឋបាលក្រុង។ ក្រសួងបរិស្ថានក៏អាចស្នើទៅក្រសួងមហាផ្ទៃឲ្យធ្វើការព្រមានទៅដល់រដ្ឋបាលក្រុងណា ដែលអនុវត្តការងារមិនមានប្រសិទ្ធភាព ឬមិនអនុវត្តតាមការណែនាំបច្ចេកទេសរបស់ក្រសួងបរិស្ថាន (MOE, MOI and MEF 2015)។

### *សមត្ថភាពនៅថ្នាក់ក្រោមជាតិ*

ដូចបានចង្អុលបង្ហាញពីខាងដើម ការផ្ទេរមុខងារនេះមិនរួមបញ្ចូលការផ្ទេរបុគ្គលិកឡើងវិញទេ ហើយរដ្ឋបាលក្រុងប្រឈមនឹងបញ្ហានេះខុសៗគ្នា។ ដោយសារអ្នកម៉ៅការឯកជនទទួលធ្វើការងារភាគច្រើនក្នុងការប្រមូលកាកសំណល់រឹង ដូច្នេះទំនួលខុសត្រូវចម្បងរបស់រដ្ឋបាលក្រុងគឺការត្រួតពិនិត្យ។ មានក្រុងពីរបានបង្កើត ក្រុមការងារដែលដឹកនាំដោយអភិបាលក្រុងរងម្នាក់ និងមានមន្ត្រីមកពីអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង និងអង្គភាពអភិវឌ្ឍន៍ក្រុង ជួយធ្វើការងារផង។ មានក្រុងមួយ បានអនុវត្តតាមវិធីសាស្ត្រចូលរួម ដោយបានបង្កើតក្រុមការងារមួយដែលដឹកនាំដោយអភិបាលរងក្រុងម្នាក់ និងមានសមាជិកជាមន្ត្រីមកពីមន្ទីរបរិស្ថានខេត្ត និងការិយាល័យបរិស្ថានក្រុង។ ដោយសារមានកម្រិតអភិឌ្ឍន៍ខ្ពស់ ក្រុងមួយទៀតមានលទ្ធភាពបង្កើតអង្គភាពជំនាញមួយ ដែលធ្វើការលើការគ្រប់គ្រងកាកសំណល់ និងសោភណភាពទីក្រុង តាំងពីមុនពេលមានការផ្ទេរមុខងារម្លេះ។ ដូច្នេះហើយរដ្ឋបាលក្រុងនោះ មានសមត្ថភាពខ្ពស់ជាងគេក្នុងការអនុវត្តមុខងារដែលផ្ទេរមក។ អ្នកឆ្លើយតបម្នាក់នៅក្រុងផ្សេងមានបំណងធ្វើសំណើទៅក្រសួងមហាផ្ទៃបង្កើតអង្គភាពស្រដៀងគ្នាមួយ ដើម្បីសម្រាលបន្ទុកការងារមន្ត្រីរបស់គាត់។ ស្រដៀងគ្នាដែរ អ្នកឆ្លើយតបម្នាក់ទៀតនៅ ក្រុងមួយទៀត បានលើកនូវក្ដីបារម្ភពីបន្ទុកការងារមមាញឹករបស់មន្ត្រីគាត់ ហើយគិតថា គួរមានការផ្ទេរបុគ្គលិក រាល់ពេលមានការផ្ទេរមុខងារថ្មីអ្វីមួយ។ តបនឹងក្ដីបារម្ភអំពីបន្ទុកងារងារនេះ អ្នកឆ្លើយតបនានានៅមន្ទីរបរិស្ថាន បាននិយាយថា កង្វះបុគ្គលិកនៅថ្នាក់ក្រោមជាតិគឺជាបញ្ហាទូទៅមួយដែលពុំមានដំណោះស្រាយងាយស្រួលទេ ដោយពួកគាត់បានលើកឡើងពីបញ្ហាដូចគ្នានៅក្នុងមន្ទីររបស់គាត់។

ទោះបីមានផលលំបាកផ្នែកធនធានមនុស្សដូច្នេះក្ដី ក៏អ្នកឆ្លើយតបគ្រប់គ្នានៅរដ្ឋបាលក្រុង បានទទួលស្វាគមន៍មុខងារថ្មីនិងច្រានចោលទស្សនៈដែលថា រដ្ឋបាលថ្នាក់ក្រោមជាតិខ្វះសមត្ថភាព។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងមួយបានលើកសំណួរថា៖

បើសិនមិនផ្ទេរមុខងារឲ្យខ្ញុំទេ តើធ្វើយ៉ាងណាអាចដឹងថា ខ្ញុំអាចធ្វើបាន ឬក៏អត់? មិនត្រូវចេះតែគិតថា ថ្នាក់ក្រោមមិនអាចធ្វើបាននោះទេ។ ប្រសិនបើពួកគេពិតជាមិនអាចធ្វើបានមែន អ្នកត្រូវកសាងសមត្ថភាពរបស់ពួកគេ។ រឿងនេះគ្មានអ្វីខុសសោះ។

អ្នកឆ្លើយតបម្នាក់ទៀត នៅរដ្ឋបាលក្រុងមួយទៀតបាននិយាយថា ការផ្ទេរមុខងារបានអនុញ្ញាតឲ្យរដ្ឋបាលក្រុងបំពេញភារកិច្ចរបស់ខ្លួន ជាជាងបន្ទោសអ្នកដទៃពីបញ្ហាផ្សេងៗ ហើយលើកទឹកចិត្តពួកគេឲ្យខំធ្វើការកាន់តែខ្លាំង ដើម្បីកុំឲ្យ "គេមើលងាយ"។

## ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

ផ្អែកលើករណីសិក្សាពីការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជនអត្ថបទនេះជាការព្យាយាមដំបូងគេមួយ ដើម្បីវាយតម្លៃពីដំណើរការ និងបញ្ហាប្រឈមនៃវិសហមជ្ឈការ។ ការផ្ទេរមុខងារពិតជាបានជួយផ្ដល់សិទ្ធិអំណាចដល់ រដ្ឋបាលក្រុង ក្នុងការផ្ដល់សេវាគ្រប់គ្រងកាកសំណល់រឹង ដោយផ្ដល់ឲ្យពួកគេនូវទំនួលខុសត្រូវកាន់តែធំ សិទ្ធិ និងថវិកាដែលចាំបាច់ ថ្វីបើការផ្ទេរបុគ្គលិក មិនស្ថិតក្នុងការផ្ទេរនេះក្ដី។ ការផ្ទេរមុខងារបានបង្វែរភារកិច្ចគ្រប់គ្រងកាកសំណល់រឹង ពីកម្រិតខេត្ត មកកម្រិតក្រុង ដោយមានអមមកមួយនូវ កញ្ចប់ថវិកាផ្ដល់ដោយក្រសួង ដែលកើនឡើងជារៀងរាល់ឆ្នាំ ហើយជំនួយគាំទ្របែបនេះអាជ្ញាធរខេត្តពុំធ្លាប់មានទេ នៅមុនពេលមានការផ្ទេរ។ កញ្ចប់ថវិកាមានទំហំធំគួរសម ប៉ុន្តែត្រូវមានច្រើនជាងនេះប្រសិនបើសេវាគ្រប់គ្រងកាកសំណល់រឹងត្រូវអភិវឌ្ឍបន្ថែម។ សិទ្ធិអំណាចរបស់រដ្ឋបាលក្រុង ក្នុងការបង្កើតប្រាក់ចំណូល តាមរយៈ ការយកកម្រៃលើការប្រមូលកាកសំណល់រឹងក្នុងពេលខាងមុខនេះ អាចជួយពង្រីកកញ្ចប់ថវិការបស់ក្រុង។

ករណីសិក្សានេះ បង្ហាញថា មកទល់សព្វថ្ងៃរដ្ឋបាលក្រុងមិនទាន់ជួបឧបសគ្គអ្វីធំដុំ ក្នុងការអនុវត្តមុខងារនោះទេ ទោះបីជាមានបញ្ហាប្រឈមខ្លះៗក្ដី។ ចំពោះទំនាក់ទំនងរវាងស្ថាប័នរបស់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិវិញ ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ជាមួយនឹងមន្ទីរបរិស្ថានខេត្ត មិនសូវផុលផុសឡើយ សម្រាប់ក្រុងដែលបានចុះសិក្សា។ ប៉ុន្តែគេអាចរំពឹងថា នឹងមានទំនាក់ទំនងកាន់តែច្រើនឡើង នៅពេលក្រសួងចាប់ផ្ដើមធ្វើអធិការកិច្ចលើការអនុវត្តមុខងារ។ ទោះជាយ៉ាងនេះក្ដី ករណីសិក្សានេះបានរកឃើញ ករណីអនុវត្តសិទ្ធិអំណាចវេតូមួយដោយមន្ទីរបរិស្ថានទៅលើសំណើរបស់រដ្ឋបាលក្រុង ដោយសារពួកគេមិនយល់ស្របគ្នានឹងសកម្មភាពដែលអាចយកថវិកាទៅចាយបាន។ ប៉ុន្តែការប្រើវេតូនោះ ផ្អែកលើការបកស្រាយរបស់មន្ទីរជំនាញពី ខ្លឹមសារនៃបទបញ្ញត្តិច្បាប់ គឺមិនមែនជាសកម្មភាពជៀតជ្រែកក្រៅផ្លូវច្បាប់ ឬ ការប្រើអំណាចរំលោភច្បាប់នោះទេ។ ព្រឹត្តិការណ៍នេះមានអត្ថន័យសំខាន់ចំពោះទំនាក់ទំនងរវាងបទបញ្ញត្តិច្បាប់នឹងអំណាចនៅថ្នាក់មូលដ្ឋាន។ ថ្វីបើការមានបទបញ្ញត្តិច្បាប់ទូលាយ អាចផ្ដល់ឱកាសច្រើនដល់ រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យធ្វើការផ្ដួចផ្ដើមគំនិត ប៉ុន្តែវាក៏បង្កើតភាពមិនច្បាស់លាស់ ដែលបើកឱកាសឲ្យមានការបកស្រាយដើម្បីបម្រើផលប្រយោជន៍ណាមួយ។ ក្នុងបរិបទដែលស្ថាប័នសម្រាប់ដោះស្រាយការខ្វែងគំនិតគ្នា ក្នុងការធ្វើសេចក្ដីសម្រេច នៅទន់ខ្សោយ ឬមិនទាន់មាននោះ សេចក្ដីសម្រេចចិត្តរបស់ថ្នាក់លើ នឹងមានអាទិភាពជាងសេចក្ដីសម្រេចចិត្តរបស់ថ្នាក់ក្រោម។ ចំពោះសមត្ថភាពវិញ រដ្ឋបាលក្រុង មានការតាំងចិត្តខ្ពស់និងត្រៀមខ្លួនជាស្រេចដើម្បីបង្ហាញឲ្យឃើញច្បាស់ពីសមត្ថភាពរបស់ខ្លួន ទោះបីមានក្ដីបារម្ភខ្លះៗពីកំណើនបន្ទុកការងារក្ដី។ ជំហរសុទិដ្ឋិនិយមនេះ ផ្ទុយនឹងទស្សនៈដែលថា រដ្ឋបាលថ្នាក់ក្រោមជាតិ ខ្វះសមត្ថភាព។ ការលើកឡើងថា ការកសាងសមត្ថភាពគ្មានអ្វីខុសទេបើសិនវានៅខ្វះខាត បង្ហាញពីការចង់បានរបស់ រដ្ឋបាលក្រុងឲ្យចាត់ទុកការខ្វះសមត្ថភាពជារឿងធម្មតាជាជាងចាត់ទុកវាជាបញ្ហាដែលរាំងស្ទះដល់ការផ្ទេរមុខងារ។

សរុបមក ករណីសិក្សានេះសន្និដ្ឋានថា ការផ្ដល់ សិទ្ធិ ទំនួលខុសត្រូវ និងធនធនច្រើនជាងមុន អាចជួយពង្រឹងតួនាទីរបស់រដ្ឋបាលក្រុង ក្នុងការអភិវឌ្ឍមូលដ្ឋាន និងលើកកម្ពស់គណនេយ្យភាព របស់រដ្ឋបាលក្រុង។ ប៉ុន្តែចំណុចនេះពិបាកសម្រេចបាន ប្រសិនបើនិន្នាការប្រមូលផ្ដុំសិទ្ធិអំណាចនៅថ្នាក់ជាតិមិនបានថយចុះព្រមគ្នាទេ។ ទោះជាយ៉ាងណាក្ដី នេះគ្រាន់តែជាសេចក្ដីសន្និដ្ឋានដំបូងប៉ុណ្ណោះ។ គេអាចមានសេចក្ដីសន្និដ្ឋានខុសគ្នា នៅពេលកំណែទម្រង់ដំណើរការទៅមុខទៀត។ វិស័យផ្សេងទៀតដែលមានភាពរសើបផ្នែកនយោបាយច្រើន ដូចជា អប់រំ និងសុខាភិបាល ជាដើម ក៏គួរធ្វើការសិក្សាដែរ ដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីដំណើរការវិសហមជ្ឈការ។

## ឯកសារយោង


Blue Media Cambodia. 2015. “Environmental Sanitation Service Budget.”

MOE, MOI and MEF (Ministry of Environment, Ministry of Interior and Ministry of Economy and Finance). 2015. *Joint Ministerial Prakas on the Usage of Sanitation Service Fund for the Implementation of Urban Solid and Liquid Waste Management of Subnational Administrations*.

NCDD (National Committee for Democratic Development). 2015. “H.E Ngoeun Chamroeun: Subnational administrations must prepared to accept functional transfer,” 22 October. http://ncdd.gov.kh/news-kh/sna_must_ready_enough_to_receive_functional_transfer/.

Pak Kimchoeun. 2011. *Fiscal Decentralisation in Cambodia: A Review of Progress and Challenges*. Working Paper Series No. 50. http://cdri.org.kh/webdata/download/ wp/wp50e.pdf.

Pak Kimchoeun and David Craig. 2008. *Accountability and Public Expenditure Management in Decentralised Cambodia*. Working Paper Series No. 38. www.cdri.org.kh/webdata/download/wp/wp38e.pdf.

RGC (Royal Government of Cambodia). 2012. *Sub-decree on the General Process of Transfer of Functions and Resources to Subnational Administrations.*

RGC. 2015. *Sub-decree on Urban Solid Waste Management.*

Sar Kheng. 2015. “Closing Remarks” at the National Workshop on 2015 Activity and Budget Plan of the National Committee for Democratic Development (NCDD-S), Phnom Penh, 4-5 February.